ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ធនាគារជាតិ នៃ កម្ពុជា

លេខ.......................................................

## សុន្ទរកថា

## ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា

## ថ្លែងក្នុងឱកាសបើកសន្និបាតបូកសរុបលទ្ធផលការងារឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០០៧ របស់ធនាគារជាតិនៃកម្ពុជា

នៅធនាគារជាតិនៃកម្ពុជា នាថ្ងៃទី២៣_២៤ ខែកក្កដា ឆ្នាំ២០០៧

សូមគោរព :

- លោកជំទាវ ទេសាភិបាលរង
- ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់ ជាទីស្នេហា

ថ្ងៃនេះ ខ្ញុំមានក្តីសោមនស្សរីករាយជាអតិបរមាដោយបានមកជួបជាមួយ លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាមន្ត្រីបុគ្គលិករបស់ធនាគារជាតិនៃកម្ពុជា ក្នុងឱកាសប្រារព្ធធ្វើសន្និបាតបូកសរុបលទ្ធផលការងារឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០០៧ របស់ធនាគារជាតិនៃកម្ពុជា ។ ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមានរបស់ លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ដែលជាតំណាងនាយកដ្ឋាននានានៅទីស្នាក់ការកណ្តាល និងសាខាធនាគារជាតិនៃកម្ពុជាខេត្ត-ក្រុង ដែលបានអញ្ជើញចូលរួមក្នុងអង្គសន្និបាតរបស់យើងនាពេលនេះ ។

ឆ្លៀតឱកាសនេះ ខ្ញុំសូមអរគុណ និងកោតសរសើរយ៉ាងខ្លាំង ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់មន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាយើង ដែលបានរួមចំណែកកសាងសមិទ្ធផលទាំងឡាយជូនធនាគារជាតិនៃកម្ពុជា ពោលគឺបានកសាងប្រព័ន្ធធនាគារយើងឱ្យមានការរីកចំរើន មានសុវត្ថិភាព មានសុខភាពរឹងមាំ និងទទួលបានការជឿទុកចិត្តបន្ថែមទៀតពីប្រជាជនទូទៅ រាជរដ្ឋាភិបាល និងសហគមន៍អន្តរជាតិ ។

លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីមេត្រី

គោលបំណងសំខាន់នៃការរៀបចំអង្គសន្និបាតរបស់យើងថ្ងៃនេះ គឺរៀបចំឡើងដើម្បីផ្សព្វផ្សាយពី :

១- សភាពការណ៍ទូទៅនៃសេដ្ឋកិច្ចពិភពលោក តំបន់ និងសេដ្ឋកិច្ចកម្ពុជានៅឆមាសទី១ ឆ្នាំ២០០៧

២- លទ្ធផលការងារដែលធនាគារជាតិនៃកម្ពុជាអនុវត្តបានក្នុងឆមាសទី១ ឆ្នាំ២០០៧



ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

## ១. សភាពការណ៍ទូទៅនៃសេដ្ឋកិច្ចពិភពលោក តំបន់ និងសេដ្ឋកិច្ចកម្ពុជា

តាមរបាយការណ៍របស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានបង្ហាញថា សេដ្ឋកិច្ចពិភពលោកនៅឆ្នាំ ២០០៧ មានអត្រាកំណើន ៤,៩% ទាបជាងអត្រាកំណើនឆ្នាំមុន ៥,៤% ខណៈដែលសេដ្ឋកិច្ចអាមេរិកមាននិន្នាការថយចុះទាបជាងឆ្នាំ២០០៦ បន្តិច ចំណែកឯអត្រាកំណើនសេដ្ឋកិច្ចសហភាពអឺរ៉ុប ប្រទេសជប៉ុន ចិន និងប្រទេសឥណ្ឌាវិញ ត្រូវបានព្យាករថានឹងកើនឡើងខ្ពស់ជាងឆ្នាំមុនបន្តិច ដោយសារតម្រូវការផលិតផលក្នុងស្រុក និងក្រៅប្រទេសកើនឡើង តម្លៃប្រេងឥន្ធនៈ ថ្លៃអចលនវត្ថុនៅលើទីផ្សារអន្តរជាតិ និងអតុល្យភាពពិភពលោកបានថយចុះព្រមទាំងភាពថមថយនៃគ្រោះធម្មជាតិ ដែលជាកត្តាអនុគ្រោះនៃការកើនឡើងនេះ ។

បើតាមការព្យាករណ៍របស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) កំណើនសេដ្ឋកិច្ចនៃក្រុមប្រទេសអាស៊ានបានកើនឡើងក្នុងកំរិត ៧,៧% ធៀបនឹង ៨,៧% នៅឆ្នាំ២០០៦ ។ ជាទូទៅ ពិភពលោកមានសុទិដ្ឋិនិយមចំពោះវឌ្ឍនភាពសេដ្ឋកិច្ច និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៅឆ្នាំ២០០៧ នេះ ។

ចំពោះសេដ្ឋកិច្ចកម្ពុជាវិញ ក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះ អត្រាកំណើនសេដ្ឋកិច្ចកម្ពុជាមានស្ថិរភាពល្អប្រសើរលើសពីការរំពឹងទុក ដោយនៅឆ្នាំ២០០៥ កំណើនផលិតផលក្នុងស្រុកដុលកើនឡើងដល់ ១៣,៥% នៅឆ្នាំ២០០៦ កើនដល់ ១០,៨% ហើយនៅឆ្នាំ២០០៧ នេះ តាមរបាយការណ៍ផ្លូវការរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានព្យាករដោយប្រុងប្រយ័ត្នថា នៅឆ្នាំ២០០៧ សេដ្ឋកិច្ចកម្ពុជានឹងមានអត្រាកំណើន ៩% និងនៅឆ្នាំ២០០៨ មានកំរិត ៧,៩% ។ អត្រាកំណើនមានល្បឿនថេរក្នុងកំរិត ៧,៥% រហូតដល់ឆ្នាំ២០១២ ។

កត្តាដែលអាចរក្សាល្បឿននៃកំណើននេះ បណ្តាលមកពីភាពអំណោយផលពី ១)-វិស័យកសិកម្ម និងសំណង់ ២)-ភាពថមថយនៃគ្រោះធម្មជាតិក្នុងតំបន់ ៣)-ការរីកចំរើននៃវិស័យទេសចរណ៍ ៤)-កំណើននៃការនាំចេញផលិតផលវាយនភណ្ឌ ៥)-ការបន្តចុះថ្លៃប្រេងឥន្ធនៈ ៦)-ស្ថិរភាពនៃអត្រាប្តូរប្រាក់ និងអតិផរណាទាបប្រែប្រួលក្នុងកំរិតអាចគ្រប់គ្រងបាន ៧)-ប្រសិទ្ធភាពនៃអន្តរការិយកម្មធនាគារនិងហិរញ្ញវត្ថុក្នុងការកៀងគរសញ្ច័យ និង*ជាពិសេស គឺ* ស្ថិរភាពនយោបាយ គឺជាកត្តាគន្លឹះសំរាប់ពង្រឹងជំនឿទុកចិត្ត និងភាពប្រាកដនៃការតំរង់ទិសវិនិយោគដើម្បីគាំទ្រដល់ដំណើរការអភិវឌ្ឍប្រទេសជាតិប្រកបដោយចីរភាព ។

## ២. លទ្ធផលការងារដែលធនាគារជាតិនៃកម្ពុជាអនុវត្តបានក្នុងឆមាសទី១ ឆ្នាំ២០០៧

ក្នុងឆមាសទី១ ឆ្នាំ២០០៧ ធនាគារជាតិនៃកម្ពុជា ក្នុងនាមជាអាជ្ញាធររូបិយវត្ថុជាតិ បានខិតខំបំពេញតួនាទីរបស់ខ្លួនក្នុងការរក្សាស្ថិរភាពថ្លៃ តាមរយៈការអនុវត្តនយោបាយរូបិយវត្ថុដោយប្រុងប្រយ័ត្ន សំដៅរួមចំណែកពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចឆ្ពោះទៅរកការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព ។

លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីមេត្រី

ជាលទ្ធផល ក្នុងរយៈពេល៦ខែ ដើមឆ្នាំ២០០៧ នេះ ធនាគារជាតិនៃកម្ពុជាសំរេចបានសមិទ្ធផលសំខាន់ៗ ដូចតទៅ :

**១)-ស្ថានភាពម៉ាក្រូសេដ្ឋកិច្ច :** ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនៅតែរក្សាភាពល្អប្រសើរនៃកំណើនជាប់ជាប្រចាំ ។ តម្លៃប្រាក់រៀលមានស្ថិរភាពល្អប្រសើរ ដោយអត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិកបានប្រែប្រួលជាមធ្យមក្នុងចន្លោះតិចជាង ១% ក្នុងរយៈពេល៦ខែដើមឆ្នាំនេះ ។ ក៏រីតអតិផរណានៃថ្លៃទំនិញប្រើប្រាស់នៅដើមឆ្នាំមានស្ថានភាពល្អប្រសើរ ដោយសារភាពអំណោយផលពីការបោះឆ្នោតឃុំ-សង្កាត់ប្រព្រឹត្តិទៅដោយរលូន នយោបាយសង្គមនិងសន្តិសុខមានស្ថិរភាពល្អ គួបផ្សំនឹងនយោបាយរូបិយវត្ថុនិងសារពើពន្ធសមស្របផង បានបង្កលក្ខណៈឱ្យមានភាពល្អប្រសើរចំពោះអត្រាប្តូរប្រាក់ និងអតិផរណា ។ នៅដំណាច់ឆ្នាំ២០០៧ ត្រូវបានគេរំពឹងថា អតិផរណាប្រែប្រួលក្នុងរង្វង់ ៣,៨% ប៉ុណ្ណោះ ។

កត្តាទាំងនេះ បានឆ្លុះបញ្ចាំងពីស្ថិរភាពរូបិយវត្ថុ និងការកើនឡើងនៃជំនឿទុកចិត្តរបស់សាធារណជនមកលើប្រាក់រៀល និងប្រព័ន្ធធនាគារទាំងមូល ។ ការគ្រប់គ្រងទុនបំរុងអន្តរជាតិ ផ្អែកលើមូលដ្ឋានប្រុងប្រយ័ត្ន និងសុវត្ថិភាពសាច់ប្រាក់ ។ គិតមកត្រឹមឆមាសទី១ ឆ្នាំនេះ ទុនបំរុងអន្តរជាតិរបស់យើងបានកើនឡើងជាង ១.៣០០ លានដុល្លារហើយ ដែលអាចធានាបាននូវការនាំចូលចំនួន ៣ ខែ ។

ក្រៅពីការចូលរួមពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ធនាគារជាតិនៃកម្ពុជាបានបន្តអនុវត្តយ៉ាងសកម្មនូវកម្មវិធីកំណែទម្រង់ទាំងឡាយ ដែលមានចែងក្នុងចក្ខុវិស័យ និងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០១-២០១០ ហើយទទួលបានលទ្ធផលគួរឱ្យកត់សំគាល់ ដូចខាងក្រោម :

**២)-ប្រព័ន្ធធនាគារ** មានការរីកចំរើនទាំងវិសាលភាព និងទំហំសកម្មភាព ហើយបានចូលរួមចំណែកកាន់តែច្រើនឡើងៗក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ។ ជាក់ស្តែង តាមរយៈអន្តរការិយកម្មធនាគារ វិនិយោគិនអាចប្រមូលទុនក្នុងស្រុកបន្ថែមប្រមាណ ៥០០លានដុល្លារ សំរាប់រួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិក្នុងឆ្នាំ២០០៦ កន្លងទៅនេះ ។ ចំពោះផ្នែកវិសាលភាព ចំនួនធនាគារនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានការកើនឡើងជាលំដាប់ តាមរយៈការចូលមកវិនិយោគរបស់វិនិយោគិនបរទេស ។ ចំណែកឯទំហំសកម្មភាពវិញ ទ្រព្យសកម្មសរុបកើនឡើង ៤២,៣២% ប្រាក់បញ្ញើកើន ៤៩,០១% និងឥណទានធនាគារពាណិជ្ជចំពោះវិស័យឯកជនកើន ៤៧,០៥% ។ ការវិវត្តជាវិជ្ជមាននេះ គួបផ្សំជាមួយនឹងការអនុវត្តវិធានការប្រុងប្រយ័ត្ន បានធ្វើឱ្យឥណទានមិនដំណើរការ (NPL) ថយចុះជាលំដាប់រហូតដល់ ៦,២% ធៀបនឹង ៥,៣៨% នៅឆ្នាំ២០០៦ ។

**៣)-វិស័យមីក្រូហិរញ្ញវត្ថុ :** បន្ទាប់ពីរាជរដ្ឋាភិបាលដែលមាន សម្តេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រី ជាប្រមុខ បានប្រកាសប្រសិទ្ធិនាមយក **ឆ្នាំ២០០៦ ជាឆ្នាំមីក្រូហិរញ្ញវត្ថុកម្ពុជា** និងបានដាក់ចេញនូវអនុសាសន៍ចំនួន ៦ចំណុច សំរាប់ឱ្យធនាគារជាតិនៃកម្ពុជាដែលជាអាជ្ញាធរអាណាព្យាបាល និងប្រតិបត្តិករមីក្រូហិរញ្ញវត្ថុអនុវត្តតាមរួចមក

ឃើញថា វិស័យនេះមានការរីកចំរើនយ៉ាងខ្លាំង និងទទួលបានការគាំទ្រពីមជ្ឈដ្ឋានក្នុង និងក្រៅប្រទេសថា **ជាវិស័យគន្លឹះក្នុងការរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា ។**

បច្ចុប្បន្ន គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានវចនាសម្ព័ន្ធដល់ជនបទ មានភាពរឹងមាំទាំងជំនឿទុកចិត្ត និងសេវាកម្ម ។ នៅឆ្នាំ២០០៦ មានអតិថិជនរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួនជាង ៤៧១ ពាន់គ្រួសារ បានទទួលឥណទានចំនួន ៣៧៤ ពាន់លានរៀល និងបានប្រើប្រាស់សេវាមីក្រូហិរញ្ញវត្ថុផ្សេងទៀត ។ បើគិតត្រឹមឆមាសទី១ ឆ្នាំ២០០៧ នេះ ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានកើនដល់ ៤៦៦ ពាន់លានរៀល បើគិតជាភាគរយកើនចំនួន ២៤.៣% និងមានអតិថិជនរហូតដល់ ៥១៩ ពាន់គ្រួសារ ។ ភាពជឿនលឿននេះ បញ្ជាក់ឱ្យឃើញថា ប្រជាពលរដ្ឋកម្ពុជា មានការយល់ដឹងពីសារៈសំខាន់នៃសេវាមីក្រូហិរញ្ញវត្ថុ និងវប្បធម៌ឥណទានកាន់តែប្រសើរឡើង ។

**៤).ការងារត្រួតពិនិត្យធនាគារ** : ធនាគារជាតិនៃកម្ពុជា ក្នុងនាមជាអាជ្ញាធរត្រួតពិនិត្យលើប្រព័ន្ធធនាគារទាំងមូល បានពង្រឹងការគ្រប់គ្រងប្រព័ន្ធធនាគារជាប់ជាប្រចាំ តាមរយៈការដាក់កម្មវិធីចុះទៅត្រួតពិនិត្យដល់ទីកន្លែង និងត្រួតពិនិត្យលើឯកសារ និងបានជំរុញឱ្យបណ្តាធនាគារពាណិជ្ជពង្រឹងការគ្រប់គ្រង និងការងារសវនកម្មផ្ទៃក្នុងរបស់ខ្លួន ព្រមទាំងឱ្យធនាគារទាំងនេះធ្វើការផ្សព្វផ្សាយរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនជាសាធារណៈដើម្បីបង្កើនជំនឿទុកចិត្តរបស់សាធារណជន មកលើប្រព័ន្ធធនាគារ ។

យើងបានបង្កើតប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ប្រយោជន៍ដើម្បីកាត់បន្ថយហានិភ័យឥណទាន ជំរុញការផ្តល់ប្រាក់កម្ចីដល់វិស័យឯកជន និងទទួលបានព័ត៌មានឥណទានជាអវិជ្ជមានពិតប្រាកដ ។ យើងក៏បានអនុវត្តនូវកម្មវិធីកុំព្យូទ័រកូប្រា (COBRA) ក្នុងគោលបំណងដើម្បីឱ្យការត្រួតពិនិត្យលើឯកសារកាន់តែស៊ីជម្រៅ និងមានប្រសិទ្ធភាពសំរាប់ការវិភាគ និងវាយតម្លៃស្ថានភាពធនាគារឱ្យកាន់តែសុក្រឹតឡើង ។

នៅឆ្នាំ២០០៧ ធនាគារជាតិនៃកម្ពុជាបានចេញផ្សាយ *"របាយការណ៍ត្រួតពិនិត្យធនាគារពាណិជ្ជប្រចាំឆ្នាំ២០០៦"* ប្រយោជន៍ដើម្បីឱ្យអ្នកដាក់ប្រាក់បញ្ញើ សាធារណជន អ្នកសិក្សាស្រាវជ្រាវ បានស្វែងយល់ឱ្យកាន់តែស៊ីជម្រៅពីប្រព័ន្ធធនាគារនៅកម្ពុជា និងអាចស្វែងយល់ពីតួនាទីរបស់ធនាគារកណ្តាលដែលជាអាជ្ញាធរត្រួតពិនិត្យ ។

**៥).ការពង្រឹងក្របខ័ណ្ឌច្បាប់** : កាលពីពេលថ្មីៗនេះ រដ្ឋសភាបានអនុម័តច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ហើយបានផ្តល់សិទ្ធិឱ្យធនាគារជាតិនៃកម្ពុជាបង្កើត និងដឹកនាំអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ (FIU) ដើម្បីអនុវត្តច្បាប់នេះ ។ ច្បាប់នេះ គឺជាយន្តការបង្កើនកិច្ចសហប្រតិបត្តិការទ្វេភាគី និងពហុភាគីជាមួយក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិក (APG) ក្នុងការប្រឆាំងនឹងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដែលពិភពលោកកំពុងយកចិត្តទុកដាក់ ។ម្យ៉ាងទៀតច្បាប់នេះ គឺជាមូលដ្ឋានគតិយុត្តិសំខាន់មួយសំរាប់គ្រប់គ្រង ទប់ស្កាត់ និងបង្ក្រាបនូវរាល់ប្រតិបត្តិការ ឬបទល្មើស ដែលទាក់ទងនឹងប្រតិបត្តិការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មនៅកម្ពុជា ហើយក៏ជាវិធានច្បាប់មួយយ៉ាងសំខាន់សំរាប់លើកមុខមាត់ប្រទេសកម្ពុជាក្នុងឆាក

អន្តរជាតិ *ជាពិសេស* ធ្វើឱ្យប្រទេសកម្ពុជាយើង អាចការពារបាននូវហានិភ័យនៃការនិយាយបំផ្លើសថាកម្ពុជា ជាប្រទេសសំរាប់សំអាតប្រាក់ និងហិរញ្ញប្បទានភេរវករ ។

យើងកំពុងរៀបចំសេចក្តីព្រាងច្បាប់ស្តីពីភតិសន្យា ។ ច្បាប់នេះគឺជាមូលដ្ឋានគតិយុត្តមួយសំរាប់ការអភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យមនៅកម្ពុជា និងសំរាប់កៀងគរប្រភពទុនរយៈពេលវែងទៅពង្រីកគំរោងវិនិយោគប្រកបដោយចីរភាព ។ ចំពោះការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុវិញ យើងបានបន្តកែលំអវិធានការប្រុងប្រយ័ត្ននិងបទប្បញ្ញត្តិមួយចំនួន ដើម្បីពង្រឹងប្រព័ន្ធធនាគារឱ្យប្រព្រឹត្តទៅដោយរលូន មានសុវត្ថិភាព និងមានប្រសិទ្ធភាព ។

**៦).យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥ :** យើងបានធ្វើបច្ចុប្បន្នកម្មចក្ខុវិស័យ និងផែនការអភិវឌ្ឍន៏វិស័យហិរញ្ញវត្ថុឆ្នាំ២០០១-២០១០ ឱ្យទៅជា **យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥** ។ ឯកសារនេះ ត្រូវបានរាជរដ្ឋាភិបាលអនុម័តធ្វើជាផែនទីវិថីសំរាប់ចង្អុលទិស និងកំណត់ដំណាក់កាលអភិវឌ្ឍន៏វិស័យធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជា ឱ្យមានប្រសិទ្ធភាព ។ យុទ្ធសាស្ត្រនេះក៏ត្រូវបានទទួលស្គាល់នៅក្នុងក្របខ័ណ្ឌជាតិ ហើយបានចែងក្នុងផែនការអភិវឌ្ឍន៏យុទ្ធសាស្ត្រជាតិឆ្នាំ២០០៦-២០១០ របស់រាជរដ្ឋាភិបាលបន្ថែមលើយុទ្ធសាស្ត្រចតុកោណ ប្រយោជន៍ដើម្បីបន្តពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ឆ្ពោះទៅរកការអភិវឌ្ឍន៏សេដ្ឋកិច្ចជាតិប្រកបដោយចីរភាព ។

ការអភិវឌ្ឍន៏ប្រព័ន្ធហិរញ្ញវត្ថុមួយរឹងមាំស្របតាមយន្តការទីផ្សារសេរី គឺត្រូវរៀបចំឱ្យមានប្រព័ន្ធហិរញ្ញវត្ថុមួយមានសុវត្ថិភាព មានការប្រកួតប្រជែងដោយស្មើភាព និងប្រសិទ្ធភាពក្នុងការកេណ្ឌប្រមូលធនធាននិងបែងចែក ធនធាននោះសំរាប់ការវិនិយោគប្រកបដោយចីរភាព និងផលិតភាពដើម្បីគាំទ្រកំណើនសេដ្ឋកិច្ចនិងកាត់បន្ថយភាពក្រីក្រ ។ លក្ខណៈពិសេសនៃផែនការអនុវត្តន៏ឯកសារយុទ្ធសាស្ត្រនេះ គឺមានភាពទន់ភ្លន់ ដោយរាជរដ្ឋាភិបាលអាចកែតម្រូវលើគោលនយោបាយចាំបាច់ ដើម្បីឆ្លុះបញ្ចាំងពីការរីកចំរើន ល័ក្ខខ័ណ្ឌនៃការប្រែប្រួលនិងមានភាពប្រាកដប្រជា ។

**៧).ការធ្វើកំណែទម្រង់រចនាសម្ព័ន្ធផ្ទៃក្នុង :** ក្នុងឆមាសទី១ ឆ្នាំ២០០៧ ធនាគារជាតិនៃកម្ពុជាបានបន្តធ្វើកំណែទម្រង់រចនាសម្ព័ន្ធរបស់អគ្គាធិការដ្ឋាន ដើម្បីពង្រឹងការងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ចឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ។ ជំហានបន្ទាប់ បន្តរៀបចំនូវលិខិតបទដ្ឋានចាំបាច់នានា ដូចជាសៀវភៅនីតិវិធីសវនកម្មសម្រាប់នាយកដ្ឋាននៅទីស្នាក់ការកណ្តាល សាខាខេត្ត-ក្រុង និងអង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា ។

ការងារសវនកម្មនៅទីស្នាក់ការកណ្តាល យើងបានចុះធ្វើសវនកម្មសាកល្បងផង និងហ្វឹកហាត់ការងារនៅការិយាល័យគ្រប់គ្រងគណនីនៃនាយកដ្ឋានប្រតិបត្តិការ នៅការិយាល័យបេឡា និងការិយាល័យគណនេយ្យជំនួយនៃនាយកដ្ឋានបោះផ្សាយ-ឃ្លាំងបេឡា នាយកដ្ឋានគណនេយ្យ និងសាខាធនាគារជាតិនៃកម្ពុជាខេត្តសៀមរាប ។

ចំពោះការងារអធិការកិច្ចវិញ យើងបានចុះឆ្លាក់ត្រួតពិនិត្យដោយមិនជូនដំណឹងជាមុន ក្នុងបំណងធានាសុវត្ថិភាពឃ្លាំង និងការគ្រប់គ្រងសាច់ប្រាក់ ។ ការងារសវនកម្ម និងអធិការកិច្ចនេះ យើងបន្តធ្វើនៅតាមនាយកដ្ឋាននានា និងសាខាធនាគារជាតិនៃកម្ពុជាផ្សេងទៀត ដើម្បីពង្រឹងការគ្រប់គ្រងប្រតិបត្តិការធនាគារកណ្តាលឱ្យប្រព្រឹត្តទៅកាន់តែមានប្រសិទ្ធភាព និងសុវត្ថិភាព ។

**លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីមេត្រី**

**៨)-ចំពោះកិច្ចសហប្រតិបត្តិការតំបន់ និងអន្តរជាតិវិញ :** នៅឆមាសទី១ឆ្នាំនេះ ធនាគារជាតិនៃកម្ពុជាមានកិច្ចសហប្រតិបត្តិការ ជាមួយ :

**មូលនិធិរូបិយវត្ថុអន្តរជាតិ** (IMF) បានមកបំពេញបេសកកម្មនៅកម្ពុជាចំនួនពីរលើក ហើយបានវាយតម្លៃថា ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចកម្ពុជា ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ មានស្ថិរភាពល្អ លើសពីការព្យាករណ៍ទុករបស់រាជរដ្ឋាភិបាល ។ IMF បានបន្តផ្តល់ *ក)*-ផ្តល់ជំនួយបច្ចេកទេសដល់ធនាគារជាតិនៃកម្ពុជាដើម្បីពង្រឹងប្រសិទ្ធភាពសវនកម្មផ្ទៃក្នុងនិងស្ថិតិជញ្ជីងទូទាត់ *ខ)*-សហការជាមួយធនាគារជាតិនៃកម្ពុជារៀបចំសិក្ខាសាលាជាតិស្តីពីការរៀបចំកម្មវិធី និងគោលនយោបាយហិរញ្ញវត្ថុ សំរាប់សេដ្ឋវិទូកម្ពុជាវ័យក្មេងមកពីរដ្ឋសភា ព្រឹទ្ធសភា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម ក្រសួងផែនការ និងធនាគារជាតិនៃកម្ពុជា ដើម្បីបង្កើនសមត្ថភាពជំនាញក្នុងការព្យាករណ៍ និងវិភាគម៉ាក្រូសេដ្ឋកិច្ច និង*គ)*-ធនាគារជាតិនៃកម្ពុជាបានទទួលក្រុមបេសកកម្មពិគ្រោះយោបល់មាត្រា IV នៃមូលនិធិរូបិយវត្ថុអន្តរជាតិ ដើម្បីវាយតម្លៃជាផ្លូវការពីស្ថានភាពល្អប្រសើរនៃកំណើនសេដ្ឋកិច្ចកម្ពុជា ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច បំណុលបរទេស និងការវិវត្តនៃកំណែទម្រង់រចនាសម្ព័ន្ធសំរាប់គាំទ្រកម្មវិធីកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល ។

**ក្រុមប្រទេសអាស៊ាន** (ASEAN) នៅដើមខែមេសា ឆ្នាំ២០០៧ នេះ កិច្ចប្រជុំរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ានលើកទី១១ និងកិច្ចប្រជុំថ្នាក់ទេសាភិបាលធនាគារកណ្តាលអាស៊ានលើកទី៣ ត្រូវបានរៀបចំឡើងនៅទីក្រុងឈៀងម៉ៃប្រទេសថៃ ។ ដោយសារកម្ពុជាធ្លាប់ធ្វើជាប្រធានអង្គប្រជុំទេសាភិបាលអាស៊ានកាលពីឆ្នាំ២០០៦ កន្លងទៅនៅប្រទេសសឹង្ហបុរី ហេតុនេះ ធនាគារជាតិនៃកម្ពុជាត្រូវបានគេអញ្ជើញចូលរួមមានលក្ខណៈជា Troika ដោយមានវត្តមានទេសាភិបាលធនាគារកណ្តាលទាំង៣ ថៃ-កម្ពុជា-វៀតណាម នៅក្នុងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ានទាំង ១០ ។

**ធនាគារអភិវឌ្ឍន៍អាស៊ី** (ADB) **និងអាជ្ញាធរពាក់ព័ន្ធ** យើងបានរៀបចំធ្វើបច្ចុប្បន្នកម្មចក្ខុវិស័យ និងផែនការអភិវឌ្ឍនវិស័យហិរញ្ញវត្ថុឆ្នាំ២០០១-២០១០ ទៅជាយុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥ ហើយត្រូវបានគណៈរដ្ឋមន្ត្រីអនុម័តកាលពីខែកុម្ភៈ និងត្រូវបាន **សម្តេច នាយករដ្ឋមន្ត្រី ហ៊ុន សែន** ប្រកាសដាក់

ឱ្យប្រើប្រាស់ជាផ្លូវការនៅក្នុងសន្និសីទថ្នាក់ជាតិស្តីពី ភាពជាដៃគូរវាងរាជរដ្ឋាភិបាលកម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ី ឆ្ពោះទៅប្រព័ន្ធហិរញ្ញវត្ថុដែលសមាហរណ៍ និងរឹងមាំ កាលពីខែមិថុនា កន្លងទៅនេះ ។

**មជ្ឈមណ្ឌល SEACEN** ធនាគារជាតិនៃកម្ពុជាបាន *ក)* -បន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយមជ្ឈមណ្ឌល SEACEN ដើម្បីផ្លាស់ប្តូរបទពិសោធន៍នៃការគ្រប់គ្រងនយោបាយរូបិយវត្ថុ និងការគ្រប់គ្រងប្រតិបត្តិការធនាគារកណ្តាល *ពិសេសគឺ* ការងារបណ្តុះបណ្តាលធនធានមនុស្ស *ខ)* -ចូលរួមកិច្ចប្រជុំគណៈកម្មការប្រតិបត្តិ SEACEN នៅប្រទេសប្រ៊ុយណេ និង *គ)* -សហការជាមួយ SEACEN ក្នុងការរៀបចំសិក្ខាសាលាអន្តរជាតិស្តីពីប្រព័ន្ធទូទាត់ និងផាត់ទាត់សំរាប់ប្រទេសកំពុងអភិវឌ្ឍន៍នៅសាខាធនាគារជាតិនៃកម្ពុជាខេត្តសៀមរាប កាលពីខែមេសា កន្លងទៅនេះ ។

**ក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិក** (APG) ក្នុងនាមជាសមាជិក ធនាគារជាតិនៃកម្ពុជាបានដើរតួនាទីចំបងក្នុងការទំនាក់ទំនង និងទទួលក្រុមបេសកកម្មវាយតម្លៃអញ្ញមញ្ញដែលដឹកនាំដោយធនាគារពិភពលោក មកបំពេញបេសកកម្មនៅកម្ពុជា ដើម្បីវាយតម្លៃពីមូលដ្ឋានច្បាប់របស់ប្រទេសកម្ពុជាក្នុងការអនុវត្តអនុសាសន៍ទាំង ៤០ ស្តីពីការប្រឆាំងការសំអាតប្រាក់ និងអនុសាសន៍ពិសេស ៩ ស្តីពីការប្រឆាំងហិរញ្ញប្បទានភេរវកម្ម ។ ជាមួយ APRACA ធនាគារជាតិនៃកម្ពុជាបានពង្រឹងកិច្ចសហប្រតិបត្តិការបណ្តុះបណ្តាល ផ្លាស់ប្តូរបច្ចេកទេសក្នុងការត្រួតពិនិត្យស្ថាប័នមីក្រូហិរញ្ញវត្ថុ និងការផ្តល់ឥណទានកសិកម្មជនបទ ។

ចំពោះទំនាក់ទំនងទ្វេភាគីវិញ ធនាគារជាតិនៃកម្ពុជាបានពង្រឹងកិច្ចសហប្រតិបត្តិការជាមួយធនាគារកណ្តាលថៃ ធនាគារកណ្តាលលុចហ្សំបួរ ធនាគារកណ្តាលប៊ែលហ្ស៊ិក ធនាគារកណ្តាលអាឡឺម៉ង់ និងធនាគារកណ្តាលនៃបណ្តាប្រទេសអាស៊ានមួយចំនួនទៀត ដើម្បីផ្លាស់ប្តូរបទពិសោធន៍ក្នុងការគ្រប់គ្រងធនាគារកណ្តាល និងការបណ្តុះបណ្តាលមន្ត្រីជំនាញរបស់យើង ។

ធនាគារជាតិនៃកម្ពុជា បានពង្រឹងប្រតិបត្តិការរបស់ខ្លួនទាំងនៅទីស្នាក់ការកណ្តាល និងសាខាខេត្ត-ក្រុង ដើម្បីចូលរួមអនុវត្តតាមកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ទទួលការបង់ពន្ធគ្រប់ប្រភេទ គ្រប់គ្រងគណនីរបស់ស្ថាប័នរដ្ឋ ចាត់ចែងសំរួលសាច់ប្រាក់តាមរយៈការបង្វែរសាច់ប្រាក់របស់រតនាគារជាតិ និងបើកប្រាក់បៀវត្សរ៍ជូនមន្ត្រីរាជការ និងកងកំលាំងប្រដាប់អាវុធគ្រប់ប្រភេទ ។

## លោកជំទាវ ឯកឧត្តម អស់លោក លោកស្រី នាងកញ្ញា ជាទីមេត្រី

សរុបមក សមិទ្ធផលទាំងនេះ គឺជាលទ្ធផលដែលកើតចេញពីការខិតខំប្រឹងប្រែងកើតចេញពីការចូលរួមនៃកំលាំងសរុបរបស់មន្ត្រីបុគ្គលិកទាំងអស់គ្នា ។ ដើម្បីជ្រាបពីសមិទ្ធផលលំអិតផ្សេងទៀត សូមអង្គសន្និបាតមេត្តាត្រងត្រាប់ស្តាប់បទឧទ្ទេសនាមរបស់មន្ត្រីរបស់យើង ដែលនឹងរាយការណ៍ជូនអង្គសន្និបាតក្នុងពេលបន្តិចទៀតនេះ ។

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះកិច្ចសហការ និងការខិតខំប្រឹងប្រែងរបស់សមាជិកក្រុមប្រឹក្សាភិបាល និងមន្ត្រីបុគ្គលិកទាំងអស់ ដែលបានរួមចំណែកធ្វើឱ្យធនាគារជាតិនៃកម្ពុជា ទទួលបានលទ្ធផលល្អប្រសើរគួរជាទីមោទនៈ ។ ខ្ញុំនៅតែមានជំនឿជឿជាក់ថា លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា នៅតែបន្តស្មារតីសាមគ្គីគ្នាជាប្រពៃណីនេះតទៀត ។ ក្នុងអង្គសន្និបាតរបស់យើងរយៈពេលពីរថ្ងៃនេះ សូម លោក លោកស្រីទាំងអស់ ខិតខំត្រងត្រាប់ស្តាប់មន្ត្រីឧទ្ទេសនាមរបស់យើងនឹងផ្សព្វផ្សាយអំពីលទ្ធផលការងារដែលបានអនុវត្តកន្លងមក និងលើកទិសដៅការងារឆ្នាំ២០០៧ សំរាប់អនុវត្តឱ្យបានជោគជ័យ ។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរដល់ លោកជំទាវ ឯកឧត្តម និងលោក លោកស្រី នាងកញ្ញា ដែលមានវត្តមាននៅក្នុងអង្គសន្និបាតនេះ សូមជួបប្រទះតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈកុំបីឃ្លៀងឃ្លាតឡើយ ហើយទន្ទឹមនេះ សូមឱ្យអង្គសន្និបាតរបស់យើងថ្ងៃនេះដំណើរការប្រកបដោយជោគជ័យ ។

ខ្ញុំសូមប្រកាសបើកអង្គសន្និបាតជាផ្លូវការចាប់ពីពេលនេះតទៅ ។

**សូមអរគុណ**